ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៤ លេខ ៣០ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ [illegible]

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

I .ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០១-៨-១៩៨៦- ព្រះរាជក្រឹត្យ នស/រកត/ ០៨៨៦/៥៣ តែងតាំងឯកឧត្តម **ថៅ ប៉េងលាត** ជាឧកញ៉ា ១៣១២

០១-៨-១៩៨៦ - ព្រះរាជក្រឹត្យ នស/រកត/០៨៨៦/៥៤ តែងតាំងលោក **មុំ សុខ** ជាឧកញ៉ា ១៣១៣

១២-៨-១៩៨៦ - ព្រះរាជក្រឹត្យ នស/រកត/០៨៨៦/៥៨ តែងតាំងលោក **គង់ ឫទ្ធីជញ** ជាឧកញ៉ា ១៣១៤

II -ទីស្តីការគណៈរដ្ឋមន្ត្រី

អនុក្រឹត្យ

០៩-៨-១៩៨៦ - អនុក្រឹត្យលេខ ១៤៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៣១៥

១៣-៨-១៩៨៦ - អនុក្រឹត្យលេខ ១៤៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៣១៦

១៤-៨-១៩៨៦ - អនុក្រឹត្យលេខ ១៤៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៣១៧

១៤-៨-១៩៨៦ - អនុក្រឹត្យលេខ ១៤៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៣១៨

១៥-៨-១៩៨៦ - អនុក្រឹត្យលេខ ១៤៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៣១៩

២_សេចក្តីសំរេច

១៣–៨–១៩៩៦ – សេចក្តីសំរេចលេខ ៣៣ សសរ ស្តីពីការផ្ទេរសិទ្ធិ ១៣២០

III -ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

០៩–៨–១៩៩៦ – ប្រកាសលេខ ២៩៨ ប្រក. សហវ. ហ ស្តីពីការកំណត់អោយអនុវត្ត កិច្ចប្រតិបត្តិការចំណាយថវិការដ្ឋតាមបរិបថ និងកំណែទម្រង់ ហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់នូវលិខិតស្នាមតាមគំរូថ្មី ១៣២២

០៩–៨–១៩៩៦ – ប្រកាសលេខ ២៩៩ ប្រក. សហវ. ហ ស្តីពីសិទ្ធិចុះទិដ្ឋាការលើ អាណត្តិបើកប្រាក់ ១៣២៩

២ -ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សារាចរណែនាំ

១៣–៨–១៩៩៦ – សារាចរណែនាំលេខ ០០៣ ស. រ ស្តីពីវិធានការដកហូតគ្រប់គ្រង និង ការប្រើប្រាស់អាវុធ ជាតិផ្ទុះគ្រប់ប្រភេទ ១៣៣៥

៣- ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

០៩–៨–១៩៩៦ – ប្រកាសលេខ ៦៨៦ អយក. ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ព សៀវភៅសិក្សាសង្គម សំរាប់គ្រូថ្នាក់ទី ១ ១៣៤០

០៩_៨_១៩៩៦ _ ប្រកាសលេខ ៦៨៧ អយក. ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ព សៀវភៅភាសាខ្មែរ សំរាប់សិស្សថ្នាក់ទី ៦ ១៣៤១

៤_ឯកសារក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

១២_៨_១៩៩៦_ ប្រកាសលេខ ១៤១ ប្រក.វវស.ប្ស ស្តីពីការបង្កើតគណៈកម្មការ មេប្រយោគទ្រទ្រង់និក្ខេបបទ ណែនាំដែលសំរាប់ការប្រឡងបញ្ចប់ បរិញ្ញា នៃមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរោបនីយវិទ្យា ឆ្នាំ ១៩៩៥_៩៦ របស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ១៣៤៣

១៥_៨_១៩៩៦ _ ប្រកាសលេខ ១៤៣ ប្រក.វវស.ប្ស ស្តីពីការទទួលស្គាល់លទ្ធផល ប្រលងយកបរិញ្ញាប័ត្រសិល្បៈផ្នែកបុរាណវិទ្យា ជំនាន់ទី ២ ឆ្នាំសិក្សា ១៩៩៤_៩៥ សម័យប្រឡង ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥ ១៣៤៤

៥_ឯកសារក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

ប្រកាស

១៣_៨_១៩៩៦ _ ប្រកាសលេខ ៧១៤ សកអ. ស្តីពីការបង្កើតការិយាល័យសុំកូន ចិញ្ចឹម ១៣៤៦

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០៨៩៦/៥៣

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

ឯកឧត្ដម ថៅ ម៉េងលាត

ជា

ឧកញ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦

ព្រះហស្ដលេខា

នរោត្ដម សីហនុ

ព្រះរាជក្រឹត្យ លេខ : នស/រកត/០៨៩៦/៥៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ម៉ុំ សុខ

ជា

ឧកញ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

ព្រះរាជក្រឹត្យ : នស/រកត/០៨៩៦/៥៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក គង់ ឫទ្ធីជព្វ

ជា

ឧកញ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

II - ទីស្ដីការគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១៤៤ អនក្រ.តត

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ជូនលោកជំទាវ STTI HEDLATI HARIYADI នាយកក្រុមហ៊ុន MAHARANY PARAMTTRA GROUP ដែលបានជួយឧបត្ថម្ភទឹកប្រាក់ចំនួន ២៧៤.៧៦១ ដុល្លារសហរដ្ឋអាមេរិក សំរាប់សាងសង់បន្ទាយកំបូល ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង នាយអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១៤៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ,
- តាមសំណើរបស់អភិបាលខេត្តកំពត

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិជូនចំពោះឯកឧត្តម **ហូ សុខ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដែលបានបរិច្ចាគថវិកាចំនួន ៤១.១៥០ ដុល្លារសហរដ្ឋអាមេរិក

សំរាប់ជួយកសាងសមិទ្ធផលផ្សេងៗ ដូចជាសាលារៀន វត្តអារាម ជីកអណ្តូងស្រះទឹក និង ផ្តល់អំណោយជាម៉ាស៊ីនបូមទឹក ម៉ាស៊ីនភ្លើងជូនដល់ប្រជារាស្ត្រនៅក្នុងមូលដ្ឋាន ខេត្តកំពត ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្តលេខា និង ត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១៤៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់តំណាងរាស្ត្រ មណ្ឌលស្វាយរៀង

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ជូនចំពោះលោកឧកញ៉ា **សៅ សេរីមុន្នី** ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចំនួន ១៨៧.៥០០ $ US សំរាប់ចូលរួមកសាងសមិទ្ធផលផ្សេងៗជូនជាតិ ជាពិសេសវិស័យអប់រំ និង សិក្សាធិការជាតិ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ : ១៤៧ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

– តាមសំណើរបស់អភិបាលខេត្តបន្ទាយមានជ័យ .

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាស ស្ថាបនាជាតិ ជូនចំពោះលោក **មុំ សុខ** នាយកក្រុមហ៊ុនសំណង់មុំ សុក M.S.C.C ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចំនួន ១២១.១១៩ $ US សំរាប់កសាង អាគារសិក្សា ០៣ ខ្នង បង្គន់អនាម័យ ០៣ ខ្នង រួម និង តុ កៅអី សំរាប់គ្រូ និង សិស្សផង នៅក្នុងខេត្តបន្ទាយមានជ័យ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ : ១៤៨ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .

– យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ម៉ៅ ថូរ៉ា** ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ជាអនុឧត្តមមន្ត្រីសេដ្ឋកិច្ចអមក្រសួងពាណិជ្ជកម្ម មានឋានៈស្មើនឹងអគ្គលេខាធិការរង សំរាប់ត្រៀមរៀបចំចូលជាសមាជិកពេញសិទ្ធិ ASEAN ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង សាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២_សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩៦

សេចក្តីសំរេច លេខ : ៣៣ សសរ

ស្តីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

សំរេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម **សុខ អាន** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជារដ្ឋលេខាធិការស្តីទី នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ជំនួសឯកឧត្តម **សូ ឃុន** ដែលត្រូវអញ្ជើញទៅបំពេញបេសកកម្មនៅបរទេស ចាប់ពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៦ រហូតដល់ឯកឧត្តមបញ្ចប់បេសកកម្ម ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **សុខ អាន** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀង ៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III - ការងារបណ្ដាក្រសួង

១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ: ២៩៨ ប្រក.សហវ.ហ

ស្ដីពីការកំណត់អោយអនុវត្តកិច្ចប្រតិបត្តិការចំណាយថវិការដ្ឋ

តាមបរិបថ និង កំណែទំរង់ហិរញ្ញវត្ថុសាធារណៈដោយប្រើ

ប្រាស់នូវលិខិតស្នាម តាមគំរូថ្មី

* * *

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តមសីហនុ វរ្ម័ន** លេខ ១០៩៤_៨៣ នស រកត ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ_បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ_បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកានៅតាមក្រសួង ខេត្ត_ក្រុងស្វ័យត រាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល

- យោងប្រកាសលេខ ២៦៨ ប្រក_សហវ_ខ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីការ តែងតាំងមន្ត្រីរាជការ ជាមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
- សារាចរណែនាំលេខ ០១២ សណន_សហវ_ថ ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ១៩៩៦ ស្តីពីវិធានការដាក់ស្តែងមួយចំនួនសំរាប់ការអនុវត្តថវិកាឆ្នាំក្នុងជំហាន២នៃកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ
- យោងតំរូវការចាំបាច់ ក្នុងកិច្ចអនុវត្តការត្រួតពិនិត្យហិរញ្ញវត្ថុតាមផែនការកែទំរង់ហិរញ្ញវត្ថុសាធារណៈ

សំរេច

ប្រការ ១ : អនុវត្តតាមបញ្ញត្តិទូទៅនៃអនុក្រឹត្យលេខ ៨១ អនក្រ_បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ សំរេចតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្នុងជំហានដំបូងអមបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នរដ្ឋបាលកណ្តាល សំរាប់អនុវត្តកិច្ចប្រតិបត្តិការត្រួតពិនិត្យហិរញ្ញវត្ថុ តាមប្រកាសលេខ ២៦៨ ប្រក_សហវ_ខ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

ប្រការ ២ : បេសកកម្មត្រួតពិនិត្យហិរញ្ញវត្ថុដែលគ្រប់គ្រងដោយនាយកដ្ឋានហិរញ្ញកិច្ច ស្ថិតក្នុងទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចាប់ផ្តើមនិងកំណត់អោយអនុវត្តកិច្ចប្រតិបត្តិការចំណាយ ថវិការដ្ឋតាមបរិបថ និង នីតិវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់នូវលិខិត ស្នាមតាមគំរូថ្មី ចាប់ពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦ តទៅ ។

ប្រការ ៣ : រាល់សំណើចំណាយថវិកា ទោ ាប្រាក់រៀល ឬ ជារូបិយប័ណ្ណបរទេសក្តី ដែលបានផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរ ញ្ញវត្ថុរួចហើយ ហើយត្រូវបានទទួលការឯកភាពនិងយល់ព្រមជាគោលការណ៍ ដើ ្បបើកផ្តល់ចំណាយនោះ ក៏ត្រូវអនុវត្តនីតិវិធីនិងលិខិតស្នាម (គំរូថ្មី) តាមកាលប ិ ទេដូចបានកំណត់ក្នុងប្រការ ២ ។

រីឯសំណុំរឿងស្នើសុំថវិកា េ ះជាប្រាក់រៀល ឬ ជារូបិយប័ណ្ណបរទេសក្តី ដែលបាន ផ្ញើមក ដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមុនថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦ ហើយពុំទាន់ បានទទួល េ ោបការណ៍ឯកភាព ដើម្បីបើកផ្តល់ចំណាយជូននៅឡើយ ក៏ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុនៅតែបន្តពិនិត្យរហូតដល់អស់

ឯកសារ តែបែបបទនៃការធ្វើ អាណត្តិកិច្ចចំណាយ គឺអនុវត្តតាមនីតិវិធីនិងលិខិតស្នាម (គំរូថ្មី) ដូចបានកំណត់ ក្នុងប្រការ ២ ខាងលើ ។

ប្រការ ៤ : –លើកលែងសាលាកប័ត្រកត់ត្រាចំណាយថវិកា និង ត្រួតពិនិត្យហិរញ្ញវត្ថុ (FICHE D' IMPUTATION BUDGETAIRE ET DE CONTROLE FINANCIER) ដែលនាយកដ្ឋានហិរញ្ញកិច្ច និង នាយកដ្ឋានគ្រប់គ្រងទុនវិនិយោគស្ថាបនាមូលដ្ឋាន បានពិនិត្យនិងបញ្ជូនទៅនាយកដ្ឋានថវិការដ្ឋត្រឹមថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា និង នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស) នឹងបន្តប្រតិបត្តិកិច្ចការនេះតាមនីតិវិធី និង អាណត្តិកិច្ចចំណាយតាមគំរូចាស់រហូតដល់អស់ឯកសារ ។

ប្រការ ៥ : –ដោយឡែក អាណត្តិកិច្ចចំណាយដែលបានទទួលហើយមិនទាន់ធ្វើការបើកផ្តល់ អង្គភាពរតនាគារត្រូវបន្តអនុវត្តការបើកផ្តល់ចំណាយរហូតដល់អស់អាណត្តិបើកប្រាក់តាមបែបគំរូចាស់ ។

ប្រការ ៦ : –នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេសក៏ត្រូវបញ្ចប់កិច្ចប្រតិបត្តិការបើកផ្តល់ចំណាយជារូបិយប័ណ្ណបរទេសមិនអោយហួសពីថ្ងៃចេញប្រកាស អោយប្រើប្រាស់លិខិតស្នាមនិងនីតិវិធីកំណែ ទំរង់ហិរញ្ញវត្ថុសាធារណៈ ដូចបានចែងក្នុងប្រការ ២ ដែរ ។

ប្រការ ៧ : –ចំពោះអាណត្តិកិច្ចចំណាយរូបិយប័ណ្ណបរទេស តាមបែបគំរូចាស់ដែលទទួលបានការឯកភាពនិងចុះហត្ថលេខា ដោយថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចហើយ ហើយមិនទាន់អនុវត្តកិច្ចការបើកផ្តល់ត្រូវបន្តអនុវត្តការបើកផ្តល់ចំណាយរហូតដល់អស់អាណត្តិបើកប្រាក់។

ប្រការ ៨ : –ចំពោះសំណើចំណាយថវិកាថ្មីចាប់ពីថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦ តទៅ ទោះជាប្រាក់រៀល ឬ ជារូបិយប័ណ្ណបរទេសក្តី គ្រប់ជំពូកនៃមាតិកាថវិកា ក្នុងដំណើរការសាកល្បងក្នុងឆមាសទី ២/៩៦ គេរៀបចំសំណុំលិខិតចំណាយភ្ជាប់ជាមួយនូវសក្ខីប័ត្រយុត្តិកម្មគ្រប់គ្រាន់ រួចផ្ញើមក ត្រួតពិនិត្យហិរញ្ញវត្ថុ (នាយកដ្ឋានហិរញ្ញកិច្ច) តាមរយៈមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទទួលបន្ទុក ដូចមានឈ្មោះក្នុងប្រកាសលេខ ២៦៨ ប្រក.សហវ.ខ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្របតាម

ខ្លឹមសារជំពូក ២ មាត្រា ៦ នៃអនុក្រឹត្យលេខ ៨១ អនក្រ_ បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។

ប្រការ ៩ : _វិធានទូទៅស្តីពីនីតិវិធីនិងបរិបថថ្មីនៃដំណាក់កាលធ្វើអាណត្តិកិច្ចចំណាយថវិការដ្ឋ ត្រូវប្រតិបត្តិតាមគំនូសនៃ " បរិបថចំណាយឆ្នាំ ១៩៩៦ " ដែលបានជូនភ្ជាប់ និង ណែនាំលំអិតក្នុងសេចក្តីណែនាំពីនីតិវិធីនិងបរិបថចំណាយថវិកាលេខ ០០៩ សហវ _ម សរណ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៦ និងសារាចរ ណែនាំ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ លេខ ០០៥ សហវ_ហ_សរណន ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ។

ប្រការ១០: _ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស រតនាគារជាតិ ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទាំងអស់និងបណ្តាក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ស្ថាប័នរដ្ឋបាលកណ្តាល មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ តាមការកំណត់ដូចបានចែងក្នុងប្រការ ២ ខាងលើចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខានិងត្រា

គាត ឈន់

* * *

ព្រះរាជាណាចក្រកម្ពុជា
[illegible] ១៩៩៦

អាណត្តិបើកប្រាក់

លេខ | | | |

ក្រសួង . | | |

ជំពូក . | | |

មាត្រា | | |

ការកត់ត្រាគណនី (ជំពូក ប្រការ គណនី អនុគណនី)	ចំនួនប្រាក់ជាលេខ	កម្មវត្ថុចំណាយ - ឈ្មោះសក្ខីប័ត្រ

ឈ្មោះ អាសយដ្ឋានអត្ថគាហក :

បែបបទទូទាត់ : ☐ ផ្ទេរ ☐ សាច់ប្រាក់

លេខគណនី :

ឈ្មោះ និង អាសយដ្ឋានធនាគារ :

កំណត់អាណត្តិនេះ ត្រឹមចំនួនប្រាក់សរុប : ....

....

ហត្ថលេខា និង ត្រា [illegible]

កាលបរិច្ឆេទ .

និដ្ឋការអភិបាលហិរញ្ញវត្ថុ :

លេខនៃការសន្យា :

ហត្ថលេខា និង ត្រា :

កាលបរិច្ឆេទ :

កន្លែងសំរាប់គណនេយ្យករ :

ចំនួនប្រាក់នៃអាណត្តិ : .... ៛

ការកាត់ទាស់និងការបកហូតទុក : .... ៛

ចំនួនប្រាក់ពិតត្រូវបើក : .... ៛

បានឃើញ. អនុញ្ញាតអោយបើកផ្តល់

ហត្ថលេខា និង ត្រា :

កាលបរិច្ឆេទ :

ក្រសួង - ជំពូក - មាត្រា : |_|_||_||_|_|

អាណត្តិបើកប្រាក់ លេខ |_|_|_|

កាលបរិច្ឆេទ :

ចំនួនប្រាក់នៃអាណត្តិ : .... ៛

ការកាត់ទាស់និងការបកហូតទុក : .... ៛

ចំនួនប្រាក់ពិតត្រូវបើក : .... ៛

កម្មវត្ថុចំណាយ :

កំណត់អាណត្តិនេះ ត្រឹមចំនួនប្រាក់ចំនួន : ....

ឈ្មោះ អាសយដ្ឋានអត្ថគាហក :

បែបបទទូទាត់ : ☐ ផ្ទេរ ☐ សាច់ប្រាក់

លេខគណនី :

ឈ្មោះ និង អាសយដ្ឋានធនាគារ :

អត្ថគាហក : *(ទូទាត់ដោយសាច់ប្រាក់)*

[illegible]

កាលបរិច្ឆេទ :

គណនេយ្យករ :

បានឃើញ. អនុញ្ញាតអោយបើកផ្តល់

កាលបរិច្ឆេទ :

ព្រះរាជាណាចក្រកម្ពុជា
គំរូប្រើប្រាស់ឆ្នាំ ១៩៩៦

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សលាកប័ត្រកត់ត្រាចំណាយថវិកា និង ត្រួតពិនិត្យហិរញ្ញវត្ថុ

លេខ |_|_|_|_|

បន្ទុកចំណាយថវិកា		ស្ថានភាពឥណទាន
ក្រសួង	|__|__|	ឥណទានអនុម័ត : ....
ផ្នែក	|__|	ការបង្វែរ : ....
ទីតាំង	|__|__|	សរុបឥណទាន ....
ជំពូក	|__|__|	ការសន្យាពីមុន ....
ប្រការ	|__|__|	ចំនួនទឹកប្រាក់ត្រូវសន្យា ....
កថាខណ្ឌ	|__|__|	
វាក្យខណ្ឌ	|__|__|	ប្រាក់ទំនេរសំរាប់ការសន្យា : ....

ប្រភេទនៃការសន្យា: ....

ផ្នែកទទួលបន្ទុកចំណាយ : ....

សក្ខីប័ត្រ ....

កន្លែងសំរាប់អាណាប័ក :	កន្លែងសំរាប់អភិបាលហិរញ្ញវត្ថុ :
ហត្ថលេខា និង ត្រា : កាលបរិច្ឆេទ :	ទិដ្ឋាការ ឬ កំណត់សំគាល់ របស់អភិបាលហិរញ្ញវត្ថុ : ....កាលបរិច្ឆេទ :
ចម្លើយតប ទៅនឹង កំណត់សំគាល់ របស់អភិបាលហិរញ្ញវត្ថុ : .... កាលបរិច្ឆេទ :	(បន្ទាប់ពីចម្លើយរបស់អាណាប័ក) ទិដ្ឋាការអភិបាលហិរញ្ញវត្ថុ : កាលបរិច្ឆេទ :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ថវិការដ្ឋ

ក្រសួង..

....

ការិយបរិច្ឆេទ

១៩៩

ជីការបលិខិតយុត្តិការ

ភ្ជាប់នឹងអាណត្តិបើកប្រាក់លេខ :....................................

នាមឥណទាយក :.....................................

Bordereau des pièces justificatives jointes au mandat de paiement.

ចំនួន	ប្រភេទលិខិតដែលផ្តល់	ចំនួនទឹកប្រាក់	ពត៌មានផ្សេងៗ
	ចំនួន		

បញ្ឈប់លិខិត ....

ជីការនេះកំណត់ចំនួនៈ ....

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ខែ ឆ្នាំ ១៩៩.....

អាណាប័ក

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ: ២៩៩ ប្រក.សហវ.ហ

ស្តីពីសិទ្ធចុះនិដ្ឋការលើអាណត្តិបើកប្រាក់

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** លេខ ១០៩៤_៨៣ នស រកត ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/៩៤ ចុះថ្ងៃទី ៣១ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ_បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- យោងប្រកាសលេខ ០០៤ សហវ_មប្រក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត_ក្រុង_ក្រុងស្វយ័ត_រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- យោងប្រកាសលេខ ០៤៨ ប្រក_សហវ_ហ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំអង្គការត្រួតពិនិត្យហិរញ្ញវត្ថុ
- យោងសារាចរណែនាំលេខ ០០៥ សហវ_ហ_សរណន ចុះថ្ងៃទី២៤ ខែ កុម្ភ ឆ្នាំ ១៩៩៦ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ
- យោងតំរូវការចាំបាច់ ក្នុងកិច្ចអនុវត្តការត្រួតពិនិត្យហិរញ្ញវត្ថុតាមផែនការកែទំរង់ហិរញ្ញវត្ថុសាធារណៈ

សំរេច

ប្រការ ១ : បទបញ្ញត្តិទូទៅនៃការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ អមតាមក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នរដ្ឋបាលកណ្តាល ព្រមទាំងអង្គការសាធារណៈរដ្ឋបាលនានានៅក្រោមចំណុះដែលមាន ចែងក្នុងអនុក្រឹត្យលេខ ៨១ អនក្រ_បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ នោះគឺជាកម្ម វត្ថុសំរាប់អនុវត្តកិច្ចប្រតិបត្តិការត្រួតពិនិត្យហិរញ្ញវត្ថុ ។

ប្រការ ២ : បេសកកម្មត្រួតពិនិត្យហិរញ្ញវត្ថុដែលគ្រប់គ្រងដោយនាយកដ្ឋានហិរញ្ញកិច្ច ត្រូវប្រតិបត្តិអោយបានម៉ឺងម៉ាត់និងពិនិត្យពិច័យបំផុត នូវការស្នើរសុំចំណាយសាធារណៈក្នុងថវិកា ជាតិដូចមាន ចែងក្នុងមាត្រា ៣ និងមាត្រា ៤ នៃអនុក្រឹត្យលេខ ៨១ អនក្រ_បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។

ប្រការ ៣ : ស្របតាមបទបញ្ញត្តិនៃមាត្រា ៣ និងមាត្រា ៤ ខាងលើនេះ រាល់សំណុំរឿងស្នើសុំចំណាយរួមទាំងអាណត្តិបើកប្រាក់ ដែលភ្ជាប់មកជាមួយនូវលិខិតយុត្តិការ និងគោលការណ៍ឯកភាពលើសំណើថវិកាជាលាយលក្ខអក្សរត្រូវតែឆ្លងការចុះទិដ្ឋាការយល់ព្រមជាមុនពីអ្នកត្រួតពិនិត្យ ហិរញ្ញវត្ថុ ។

ប្រការ ៤ : ទិដ្ឋាការលើអាណត្តិបើកប្រាក់ អ្នកត្រួតពិនិត្យហិញ្ញវត្ថុចាំបាច់ត្រូវធ្វើការត្រួតពិនិត្យអំពីភាពត្រឹមត្រូវនៃលិខិតយុត្តិការភ្ជាប់តាមសំណុំរឿងស្នើសុំចំណាយអោយបានល្អិតល្អន់បំផុត ដូចមានចែងក្នុងជំពូកទី ១ មាត្រា ៤ នៃអនុក្រឹត្យលេខ ៨១ អនក្រ_បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ។

ប្រការ ៥ : _របៀបរបបការងាររបស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ ឬ បែបបទនៃការចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ត្រូវអនុញ្ញាតនិងប្រគល់សិទ្ធអនុវត្តតាមឋានានុក្រម នៃតួនាទីមាន: ដោយផ្ទាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ៦ : សង្វាក់នៃកិច្ចប្រតិបត្តិការត្រួតពិនិត្យ និង ចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ត្រូវបានកំណត់និងស្ថិតក្នុងរង្វង់នៃតួនាទីនិងឋានានុក្រមរដ្ឋបាលដូចខាងក្រោម ÷

១_មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានសិទ្ធចុះទិដ្ឋាការត្រឹមក្រោម ២០ (ម្ភៃ) លានរៀល

២_ប្រធាននាយកដ្ឋានហិរញ្ញកិច្ច មានសិទ្ធចុះទិដ្ឋាការ ត្រឹមក្រោម ៥០ (ហាសិប) លានរៀល

៣_អាណត្តិបើកប្រាក់ដែលមានចំនួនលើសពី ៥០ លានរៀល ឬ ថវិកាមានទ្រង់ទ្រាយធំនិង មិនកំណត់ទិដ្ឋាការចំណាយត្រូវបានផ្តល់ដោយផ្ទាល់ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ៧ : ល័ក្ខខ័ណ្ឌទូទៅនៃកិច្ចប្រតិបត្តិការរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ÷

១_មានសិទ្ធចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ដែលមានចំនួនមិនកំណត់ (លើសពី ២០ លានរៀល)

ចំពោះតែ ÷

- ប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេង ៗ ដែលមានឯកសារភ្ជាប់តាមស្របច្បាប់និងមានចុះ ទិដ្ឋាការយល់ព្រមដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ថ្លៃឈ្នួលពលករអណ្តែតដែលមានច្បាប់អនុញ្ញាត និងមានទិដ្ឋាការយល់ព្រមដោយរដ្ឋ_ លេខាធិការដ្ឋានមុខងារសាធារណៈ
- ប្រាក់កំរៃលើសម៉ោងក្នុងកម្មវិធីការងារដែលមានគោលការណ៍អនុញ្ញាត និងត្រឹមត្រូវតាម គោលរបបហិរញ្ញវត្ថុ ។
- ចំណាយអន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ [illegible]មាន ÷
  * ចំណាយសង្គមកិច្ចផ្ទាល់(ជំពូក ៣១.០១.០១ពីវាក្យខ័ណ្ឌ០១ដល់១១)
  * ចំណាយអាហារូប[illegible]ណ៍(ជំពូក ៣១.០១.០២ ពីវាក្យខ័ណ្ឌ០១ដល់០៥)

  ដែលមានរបបត្រឹមត្រូ[illegible]តាមលក្ខណការណ៍ហិរញ្ញវត្ថុនិងលិខិតបញ្ជាក់ច្បាស់លាស់ពីក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ។

អាណត្តិបើកប្រាក់ដូច[illegible]រាយមុខចំណាយខាងលើ និយាយដោយឡែកក្រសួងការពារជាតិ និង ក្រសួង[illegible]ហាផ្ទៃ បើមានចំនួនថវិកាទ្រង់ទ្រាយធំ ឬ មានភាពស្មុគស្មាញមិនអាចដោះស្រាយ[illegible]ាន ស្នើបញ្ជូនមកនាយកដ្ឋានហិរញ្ញកិច្ច ដើម្បីពិនិត្យនិងមានវិធានការដោះ ស្រា[illegible]តាមលក្ខណការណ៍ហិរញ្ញវត្ថុ ។

[illegible]_ត្រូវអោយមានគោលការណ៍ឯក[illegible]ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ [illegible]មុន :

កម្មវត្ថុចំណាយទាំងឡាយដែល[illegible]ស្ថិតក្នុងក៏រិតកំណត់នៃសិទ្ធិចុះទិដ្ឋាការ (ក្រោម ២០ លានរៀល) បើ[illegible]គោលការណ៍ ឬ លិខិតបទដ្ឋាននៃច្បាប់

ជាធរមាន ត្រូវបញ្ជូនសំណុំរឿងមកនាយកដ្ឋានហិរញ្ញកិច្ច ដើម្បីធ្វើការពិនិត្យ និង ស្នើសុំគោលការណ៍សំរេចពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាមុនជាអាទិ ÷

- មុខចំណាយទាំងអស់ដូចមានអត្ថន័យចែងក្នុងមាតិកានៃថវិការដ្ឋ តែគ្មានបទដ្ឋានចំណាយត្រឹមត្រូវនិងគោលការណ៍ ...ហិរញ្ញវត្ថុជាធរមានឬទាក់ទិនដល់ចំណាយរូបិយវត្ថុអន្តរជាតិ
- សោហ៊ុយបេសកកម្មក្រៅប្រទេស
- ចំណាយក្រៅគំរោងអនុម័តប្រចាំឆ្នាំ តែមានចាំបាច់បំរើអោយផលប្រយោជន៍សង្គមជាតិ ។
- ចំណាយសង្គ្រោះបន្ទាន់ ឬ គ្រោះធម្មជាតិ

៣-ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច (ជំពូក ១១)

អាណត្តិកិច្ចចំណាយទាំងឡាយដែលភ្ជាប់មកជាមួយនូវលិខិតយុត្តិការគ្រប់គ្រាន់ ត្រឹមត្រូវតាមលិខិតបទដ្ឋាន គោលការណ៍ សារាចរណែនាំ និងនីតិវិធីហិរញ្ញវត្ថុជាធរមាន មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានកាតព្វកិច្ចអនុវត្តកិច្ចប្រតិបត្តិការបើកផ្តល់ ចំណាយ និងមានសិទ្ធចុះទិដ្ឋាការលើអាណត្តិបើកប្រាក់មិនលើសពីកំរិតកំណត់ ក្នុងប្រការ ៦-១ ។

៤-ឥណទានសាងសង់ ទិញសំភារៈ សំភារៈប្រណីត ឬ ការទូទាត់ជាលក្ខណៈអន្តរជាតិដែលស្នើចំណាយជារូបិយវត្ថុអន្តរជាតិ :

ទោះសំណើចំណាយថវិកាស្ថិតក្នុងកំរិតកំណត់ប្រគល់សិទ្ធិក្តី (ក្រោម ២០ លានរៀល) មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបញ្ជូនសំណុំរឿងទាំងអស់មកនាយកដ្ឋានហិរញ្ញកិច្ច ដើម្បីពិនិត្យនិងមានវិធានការស្នើសុំយោបល់សំរេចពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អាណត្តិបើកប្រាក់ ត្រូវបានប្រគល់សិទ្ធអោយចុះទិដ្ឋាការតាមកំរិតកំណត់ ឬ ផ្តល់ដោយផ្ទាល់ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ចំណុចពិសេសដោយឡែកនៃសំណើចំណាយថវិកាខាងលើ (៣ + ៤) គឺក្នុងលក្ខខ័ណ្ឌត្រួតពិនិត្យ និងកាត់បន្ថយការចំណាយមិនសមស្រប ឬ សំភារៈ

ប្រណីតៗ លើសពីតំរូវការនឹងសារាចរណែនាំ ឬ ក្នុងស្ថានភាពណាមួយដែលថវិការដ្ឋកំពុងជួបការលំបាក ។

សំខាន់ជាងនេះ ក៏គឺក្នុងគោលដៅពិនិត្យពីតុល្យភាពថវិកាជាមុន មុននឹងអនុញ្ញាតអោយរៀបចំធ្វើអាណត្តិកិច្ចចំណាយ និង បញ្ជូនទៅអង្គភាពរតនាគារជានាមានសាច់ប្រាក់ ។

ប្រការ ៨ : ក្រៅពីសិទ្ធប្រគល់ទិដ្ឋាការលើអាណត្តិបើកប្រាក់ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រូវប្រកាន់ខ្ជាប់នូវ ទស្សនៈនៃការទទួលខុសត្រូវដែលបានកំណត់ដោយច្បាប់ សំខាន់ប្រតិបត្តិអោយមានប្រសិទ្ធភាពនូវសារាចរណែនាំលេខ ០០៥ សហវ.ហ.សរណន ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ ។

ប្រការ ៩ : ប្រធាននាយកដ្ឋានហិរញ្ញកិច្ចមានភារកិច្ច :

* ប្រតិបត្តិតាមប្រការ ២ នៃប្រកាសលេខ ០៤៨ ប្រក_សហវ_ហ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៨៦ ស្តីពីការរៀបចំអង្គការត្រួត ពិនិត្យហិរញ្ញវត្ថុ ។

* ត្រួតពិនិត្យគ្រប់គ្រង និងទទួលខុសត្រូវនូវក្របខ័ណ្ឌអនុវត្តការត្រួតពិនិត្យហិរញ្ញវត្ថុ សំខាន់អំពីយន្តការនិងនីតិវិធីនៃកិច្ចប្រតិបត្តិការត្រួតពិនិត្យព្រមទាំងចាត់ចែងរាល់កិច្ចការទាំងឡាយដែល ជាបន្ទុករបស់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុ សំដៅសំរេចបានជាចុងក្រោយនូវរបាយ ការណ៍ត្រួតពិនិត្យជាប្រចាំ ។

បន្ថែមលើកិច្ចការទូទៅ ប្រធាននាយកដ្ឋានហិរញ្ញកិច្ចមានតួនាទី ÷

– ទទួលខុសត្រូវរួមលើគ្រប់កម្មវត្ថុចំណាយក្រៅគំរោងអនុម័តប្រចាំឆ្នាំឬ គ្មានគោលការណ៍ និង បទដ្ឋានត្រឹមត្រូវដែលបញ្ជូនឡើង ដោយមន្ត្រីត្រួតពិនិត្យ ហិរញ្ញវត្ថុអមបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន និង ស្ថាប័ន រដ្ឋបាលកណ្តាល ។

– ពិនិត្យលើសំណើផ្តល់ទុនបន្ថែម (ជំពូក ៣០.០១) ឬឧបត្ថម្ភកធន អាជីវកម្ម (ឧបត្ថម្ភប្រាក់ខាត : ជំពូក ៣០.០២) អោយសហគ្រាស សាធារណៈដែលមានផែនការខាត ឬ ក្ស័យធនសំរាប់ធានាដល់ការ បើកប្រាក់បៀវត្សដំណើរការអាជីវកម្ម ឬ ខូចខាតដោយគ្រោះធម្មជាតិ ឬ ខ្មាំងបំផ្លាញ ។ ល ។ ដោយស្នើសុំអោយមានភ្ជាប់ជាមួយនូវ ÷

✦ តារាងបៀវត្សស្របច្បាប់ និង ចុះទិដ្ឋាការដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

✦ តំរោងចំណាយត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ឬ ថ្លៃ

✦ របាយការណ៍ជំរះបញ្ជីត្រួតពិនិត្យដោយនាយកដ្ឋានរបបគណនេយ្យ នៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលតួលេខពិតជាបានបញ្ជាក់ថាខាត ឬ បាតអាជីពប្រាកដមែន ដើម្បីលើកយោបល់ និង ស្នើសុំសេចក្តី សំរេចជាគោលការណ៍ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ១០: ប្រធាននាយកដ្ឋានហិរញ្ញកិច្ចមានសិទ្ធចុះទិដ្ឋាការ :

– លើអាណត្តិបើកប្រាក់ ដែលបានកំណត់ក្នុងប្រការ ៦–២

– លើអាណត្តិបើកប្រាក់ទាំងឡាយដែលរដ្ឋមន្ត្រីបានផ្ទេរសិទ្ធ

– លើអាណត្តិប្រភាគ (MANDAT FRACTIONNE) នៃកិច្ចសន្យាចំណាយដែលមានគោលការណ៍ឯកភាពជាធរមានរួចហើយ ហើយចំនួនទឹកប្រាក់ក្នុងអាណត្តិបើកប្រាក់ មិនលើសពី ៥០ លានរៀល ឬ លើសពីនេះតាមការផ្ទេរសិទ្ធរបស់រដ្ឋមន្ត្រី ។

ប្រការ ១១: ករណីអវត្តមានក្នុងក្របខ័ណ្ឌនៃច្បាប់ ÷

១– អនុប្រធាននាយកដ្ឋានទី ១ ទទួលបន្ទុកអចិន្ត្រៃយ៍ មានសិទ្ធចុះទិដ្ឋាការលើអាណត្តិបើក ប្រាក់ជំនួស ប្រធាននាយកដ្ឋានតាមការផ្ទេរសិទ្ធ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

២– មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលមានឋានៈបន្ទាប់ អាចមានសិទ្ធចុះទិដ្ឋាការជំនួស (ប្រធាន) បានលុះត្រាតែមានសំណើមកនាយកដ្ឋានហិរញ្ញកិច្ច ដើម្បីចាត់វិធានការប្រគល់សិទ្ធជំនួស តាមឋានានុក្រមរដ្ឋបាល ។

ប្រការ ១២ : ក្នុងពេលអនុវត្តប្រកាសនេះ ប្រសិនណាមានជួបការលំបាកដោយប្រការណាំមួយ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ អាចនឹងអញ្ជើញមកទាក់ទងផ្ទាល់ ឬ តាមលិខិតស្នាមផ្ញើមកនាយកដ្ឋានហិរញ្ញកិច្ច ដើម្បីពិនិត្យដោះស្រាយ ឬ លើកយោបល់សុំការណែនាំថ្នាក់ដឹកនាំក្រសួង ។

ប្រការ ១៣ : ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរ នាយកដ្ឋានថវិកានាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស នាយកដ្ឋានគ្រប់គ្រងទុនវិនិយោគនិងស្ថាបនាមូលដ្ឋាននាយកដ្ឋានទ្រព្យរដ្ឋ រតនាគារជាតិ ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធ

ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចេញប្រកាសកំណត់ផ្តើមកិច្ចប្រតិបត្តិការត្រួតពិនិត្យហិរញ្ញវត្ថុជាផ្លូវការ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខានិងត្រា
គាត ឈន់

* * *

២ -ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សារាចរណែនាំ

ភ្នំពេញ,ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩៦

លេខ : ០០៣ ស.រ សារាចរណែនាំ

ស្តីពីវិធានការដកហូតគ្រប់គ្រង និង

ការប្រើប្រាស់អាវុធ ជាតិផ្ទុះគ្រប់ប្រភេទ

* * *

ដើម្បីធានាការអនុវត្តន៍តាមខ្លឹមសារនៃអនុក្រឹត្យលេខ៦២ អនក្រ. ចុះថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងការប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ អោយមាន ប្រសិទ្ធិភាព ក្រសួងមហាផ្ទៃណែនាំ វិធានការដកហូតគ្រប់គ្រង និង ការប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទដូចតទៅ ÷

១— វិធានការដកហូត :

យោងតាមមាត្រា ៨ មាត្រា ៩ និង មាត្រា១០ នៃអនុក្រឹត្យលេខ ៦២ អនក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ ជនដែលអាចអនុញ្ញាតអោយ ប្រើប្រាស់អាវុធខ្លីជាលក្ខណៈបុគ្គលបានក្នុងពេលបំពេញបេសកម្មតាមការកំណត់ថ្នាក់ដូចខាងក្រោម ÷

ក– ចំពោះមន្ត្រីរាជការស្ថាប័នស៊ីវិល :

– នៅក្រសួង ស្ថាប័នចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋានឡើងទៅ ។

– នៅខេត្ត ក្រុង ចាប់ពីថ្នាក់អភិបាលរងខេត្ត–ក្រុង ឡើងទៅ និង ចៅក្រសួងជុំវិញខេត្ត–ក្រុង ។

– នៅខ័ណ្ឌ ស្រុក គឺអភិបាល និង អភិបាលរង ស្រុក ខ័ណ្ឌ ។

ខ– ចំពោះកងកម្លាំងនគរបាលជាតិ :

– អ្នកមានឋានៈ មុខងារ ចាប់ពីថ្នាក់អនុប្រធានការិយាល័យ និង ថ្នាក់អនុប្រធានកងអនុសេនាតូចឡើងទៅ ។

– ភ្នាក់ងារ ឬ មន្ត្រីនគរបាលជាតិ ដែលទទួលបទបញ្ជាអោយបំពេញភារកិច្ចការពារថ្នាក់ដឹកនាំជាន់ ខ្ពស់ ឬ អោយទៅបំពេញបេសកកម្មជំនាញនៅតំបន់អសន្តិសុខ ។

គ– ចំពោះមន្ត្រីគយ ពន្ធដារ រុក្ខាប្រមាញ់ ជលផល ក្រុមហ៊ុនចំការកៅស៊ូរដ្ឋ បរិដ្ឋាន និង ធនាគារជាតិនៃកម្ពុជា :

– អ្នកមានឋានៈមុខងារចាប់ពីថ្នាក់អនុប្រធានការិយាល័យឡើងទៅ ។

ក្រៅពីអ្នកមានសិទ្ធិប្រើប្រាស់អាវុធខ្លីជាលក្ខណៈបុគ្គលដូចមានចែងក្នុងចំណុច ក,ខ និង គ ខាងលើនេះ ក្រសួងមហាផ្ទៃមិនចេញលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធខ្លីនេះ ជាលក្ខណៈបុគ្គល ហើយ លិខិតអនុញ្ញាតដែលចេញអោយពីមុនត្រូវទុកជាមោឃៈ ចាប់ពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៦ និង ត្រូវអនុវត្តវិធាន ការដកហូតដូចខាងក្រោមនេះ ÷

– ប្រធានក្រសួង ស្ថាប័ននានា ត្រូវចាត់វិធានការប្រមូលអាវុធខ្លីពីមន្ត្រីរាជការស៊ីវិលក្រោមឱវាទខ្លួនគ្រប់គ្រងទាំងអស់រួចធ្វើបញ្ជីតាមគំរូជូនភ្ជាប់មកជាមួយនេះ រួចបញ្ជូនមកមកនាយកដ្ឋាន នគរបាលរដ្ឋបាលនៃក្រសួង មហាផ្ទៃអោយបានមុនថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៦ ។

– នាយកខុទ្ទកាល័យ នៃក្រសួងមហាផ្ទៃ អគ្គនាយកនគរបាលជាតិ អគ្គនាយករដ្ឋបាលអគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាពអន្តរាគមន៍ ប្រធានការិយាល័យនគរបាលអន្តរជាតិចំណុះក្រសួងមហាផ្ទៃ អភិបាល ខេត្ត–ក្រុង និង ស្នងការនគរបាលខេត្ត–ក្រុង ត្រូវចាត់វិធានការប្រមូលអាវុធខ្លីពីមន្ត្រីនគរបាលជាតិ ឬ មន្ត្រី រដ្ឋបាលដែលស្ថិតនៅក្រោមឱវាទខ្លួនគ្រប់គ្រងទាំងអស់ រួចធ្វើបញ្ជីតាមគំរូជូនភ្ជាប់មកជាមួយនេះ រួចបញ្ជូនមក នាយកដ្ឋាននគរបាលរដ្ឋបាល នៃក្រសួងមហាផ្ទៃអោយបានមុន ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៦ ។

ដោយខ្សែកអាវុធវែង មិនអនុញ្ញាតអោយប្រើប្រាស់ជាលក្ខណៈបុគ្គលឡើយ ។ ដូច្នេះ អាវុធវែងដែលបុគ្គលមានពីមុន ទោះជាមានលិខិតអនុញ្ញាតអោយប្រើប្រាស់ក៏ដោយ ក៏ត្រូវដកហូតទាំងអស់ និង ត្រូវអនុវត្តវិធានការដកហូត ដូចការដកហូតអាវុធខ្លីខាងលើនេះ ។

២—វិធានការគ្រប់គ្រង :

ក— អាវុធវែងអង្គភាព ស្ថាប័ន ជាអ្នកគ្រប់គ្រង និងត្រូវធ្វើពាក្យសុំអនុញ្ញាតច្បាប់ប្រើប្រាស់មក ÷

— នាយកដ្ឋាននគរបាលរដ្ឋបាល ចំពោះអាវុធវែងដែលប្រើប្រាស់នៅតាមអង្គភាពចំណុះទីស្តីការរដ្ឋ មន្ត្រីក្រសួងមហាផ្ទៃ និង ក្រសួង ឬ ស្ថាប័ននានាដែលមានទីតាំងនៅក្រុងភ្នំពេញ ។

— ស្នងការនគរបាលខេត្ត–ក្រុង ចំពោះអាវុធវែង ដែលប្រើប្រាស់នៅអង្គភាពចំណុះស្នងការនគរបាល ខេត្ត–ក្រុង សាលាខេត្ត–ក្រុង–ស្រុក ខ័ណ្ឌ និង ទៅក្រសួងនានាជុំវិញខេត្ត–ក្រុង ។

ខ— អាវុធខ្លីដែលប្រើប្រាស់ជាលក្ខណៈបុគ្គល សាមុីខ្លួនជាអ្នកគ្រប់គ្រង និងទទួលខុសត្រូវផ្ទាល់ខ្លួន ។

គ— អាវុធធុនធ្ងន់ គ្រប់ប្រភេទ គ្រាប់បែក គ្រាប់មីន ទាំងអស់ដែលប្រើប្រាស់ក្នុងកងកម្លាំង នគរបាលជាតិ ត្រូវប្រធានអង្គភាពទទួលបន្ទុកជាអ្នកគ្រប់គ្រងនិងទទួលខុសត្រូវផ្ទាល់ ។

៣—វិធានការប្រើប្រាស់ :

ក—អាវុធវែង អាចប្រើប្រាស់សំរាប់ការពារក្រសួង ស្ថាប័ន អង្គភាព ឃ្លាំង ឬគោលដៅសំខាន់ ៗ និង យកតាមខ្លួនបានពេលចុះបំពេញបេសកកម្មនៅតាមតំបន់អសន្តិសុខ និង ការពារលំនៅដ្ឋាន នៃសមាជិករាជរដ្ឋាភិបាល សមាជិកសភាជាតិ និង លំនៅដ្ឋាន វរជនសំខាន់ងទៀតដែលរាជរដ្ឋាភិបាលបានសំរេចទទួលស្គាល់ ។ ហាមប្រើប្រាស់អាវុធវែង ចុះបំពេញបេសកកម្មធម្មតា ក្នុងទីប្រជុំជន ខេត្ត–ក្រុង លើកលែងតែ បេសកកម្មចុះបង្ក្រាប និង បង្ក្រាបចោរប្លន់ប្រដាប់អាវុធ ឬ ភេរវកម្ម ។

ខ—អាវុធខ្លីប្រើប្រាស់យកតាមខ្លួនបានពេលចុះបំពេញបេសកកម្ម ក្រៅពីបំពេញបេសកកម្មត្រូវរក្សាទុកនៅផ្ទះ ឬ កន្លែងធ្វើការរបស់ខ្លួន ។ ហាមអោយគេខ្ចីប្រើ ឬ យកទៅផ្ញើទុកជាមួយអ្នកដទៃ ។

គ–អាវុធ ធុនធ្ងន់ គ្រាប់បែក គ្រាប់មីន អាចប្រើប្រាស់បានពេលចុះយុទ្ធនាការបោសសំអាត ក្រុម ឧទ្ទាមតាមបញ្ជា នៃសហអគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ឬ ការពារទីតាំងយុទ្ធសាស្ត្រនានាតាម បញ្ជារបស់សហនាយករដ្ឋមន្ត្រី ឬ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ឃ–អាវុធប្រមាញ់ហាមប្រើប្រាស់ជាដាច់ខាត ដើម្បីការពារបរិដ្ឋាននិងសត្វគ្រប់ប្រភេទ ។ ក្នុង ករណីល្មើស ត្រូវរឹបអូសយកអាវុធទាំងនោះទុកជាសម្បត្តិរដ្ឋ ។ ករណីរឹងរូសត្រូវចាប់បញ្ជូនខ្លួនទៅតុលាការផ្តន្ទាទោសតាមច្បាប់ ។

៤–វិធានការចាត់តាំង និង ការពារសុវត្ថិភាពក្រោយពីការដកហូតអាវុធគ្រប់ប្រភេទ :

ក្រោយការដកហូតអាវុធគ្រប់ប្រភេទ ក្រុមហ៊ុន សហគ្រាស ឬ មូលដ្ឋានអាជីវកម្ម សិប្បកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ឬធនាគារ មានការចាំបាច់ត្រូវការពារទីតាំងរបស់ខ្លួនត្រូវធ្វើពាក្យស្នើសុំមក ក្រសួងមហាផ្ទៃ នៅភ្នំពេញ ឬ មកស្នងការដ្ឋាននគរបាលខេត្ត–ក្រុង នៅខេត្ត–ក្រុង ដើម្បីពិភាក្សា និង ចាត់តាំងកម្លាំងនគរបាល តាមចំនួនសមស្របដើម្បីធានាការពារសុវត្ថិភាពជូនតាមសំណូមពរ ។

៥–វិធានការប្រតិបត្តិ និង ការដាក់ទោស :

គ្រប់កងកម្លាំងនគរបាលជាតិ មន្ត្រីរដ្ឋបាល មន្ត្រីរាជការស៊ីវិល និង ប្រជារាស្ត្រ ត្រូវប្រតិបត្តិតាមសារាចរនេះ ។ ក្នុងករណីរឹងរូសមិនប្រតិបត្តិតាមខ្លឹមសារដូចមានចែងក្នុងចំណុចទី១ ។ ចំណុចទី២ ចំណុចទី៣ និង ចំណុចទី៤ នៃសារាចរនេះ ជននោះត្រូវផ្តន្ទាទោសពិន័យផ្នែករដ្ឋបាល និង រឹបអូស អាវុធជាតិផ្ទុះទាំងនោះទុកជាសម្បត្តិរដ្ឋ ។ ក្នុងករណីធ្ងន់ធ្ងរត្រូវបញ្ជូនខ្លួនទៅតុលាការផ្តន្ទាទោស តាមមាត្រា២ មាត្រា៣ មាត្រា៤ ឬ មាត្រា ៥ នៃច្បាប់ស្តីពីការផ្តន្ទាទោសការកាន់អាវុធ និងការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ជា ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ១១ក្រ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

ចំពោះជនបរទេសទាំងអស់ក៏ត្រូវប្រតិបត្តិ តាមខ្លឹមសារ នៃសារាចរនេះទាំងស្រុង ។

សារាចរនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា និងត្រា

ស ខេង យូ ហុកគ្រី

គំរូបញ្ជីដកហូតអាវុធគ្រប់ប្រភេទ

ស្រង់រាយនាម និង ចំនួនអាវុធដែលបានដកហូត

ពីថ្ងៃទី ខែ ដល់ថ្ងៃទី ខែ ឆ្នាំ ១៩៨៦

ល.រ	ឈ្មោះអ្នកត្រូវដកហូតអាវុធ	ចំនួនអាវុធ		ម៉ូដ (ផលិតនៅប្រទេស)	លេខអាវុធ	ចំនួនគ្រាប់	ចំនួនប៉ាក់	ផ្សេងៗ
		ខ្លី	វែង					
១								
២								
៣								
៤								
៥								
៦								
៧								
៨								
៩								
១០								
១១								
១២								
១៣								
១៤								
១៥								
	ចំនួនសរុប							

លេខ :............

បានឃើញ និងឯកភាព

ថ្ងៃទី ខែ ឆ្នាំ ១៩៨៦ ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ ១៩៨៦

ប្រធានក្រសួង ឬ ស្ថាប័ន ឬអង្គភាព អ្នកធ្វើបញ្ជី

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

ប្រកាស

ភ្នំពេញ, ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៦៨៦ អយក.ប្រ.ក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅសិក្សា

សង្គមសំរាប់គ្រូថ្នាក់ទី១

* * *

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ កម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពី ការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣១៨ អយក.ឧទទ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអ ប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅសិក្សាសង្គមសំរាប់ គ្រូថ្នាក់ទី១ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦

សំរេច

ប្រការ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅសិក្សាសង្គមសំរាប់គ្រូ ថ្នាក់ទី១ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការសិក្សាសង្គម បឋមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា រៀបរៀងដោយអ្នកស្រី **យិន វ៉ានថា** ដើម្បីប្រើប្រាស់នៅតាមសាលារៀនចំនេះទូទៅ ។

ប្រការ២ : មន្ទីរ នាយកដ្ឋានចាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវគ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយបណ្ណាល័យនាយកដ្ឋានចំនេះទូទៅនិងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និងត្រា

តុល ឡោះ

* * *

ភ្នំពេញ,ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ៦៨៧ អយក.ប្រ.ក

ស្តីពីការអនុញ្ញាតអោយបោះពុម្ពសៀវភៅភាសាខ្មែរ

សំរាប់សិស្សថ្នាក់ទី៦

* * *

រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ កែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានពិនិត្យលិខិតឧទ្ទេសនាម លេខ ៣១៨ អយក.ឧទន ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបង្កើតគណៈកម្មការកែលំអប្រព័ន្ធអប់រំ
- បានពិនិត្យរបាយការណ៍របស់គណៈកម្មការ ពិនិត្យខ្លឹមសារសៀវភៅភាសាខ្មែរសំរាប់សិស្សថ្នាក់ទី៦ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៦

សំរេច

ប្រការ១ : អនុញ្ញាតអោយបោះពុម្ពផ្សាយសៀវភៅភាសាខ្មែរ សំរាប់សិស្សថ្នាក់ទី៦ ដែលជាស្នាដៃនិពន្ធរបស់គណៈកម្មការភាសាខ្មែរ បឋមសិក្សានៃវិទ្យាស្ថានស្រាវជ្រាវក្រសួងអប់រំ យុវជន និងកីឡា រៀបរៀងដោយលោកស្រី **លី សុមុនី** ដើម្បីប្រើប្រាស់នៅតាមសាលារៀន ចំនេះទូទៅ ។

ប្រការ២ : មន្ទីរ នាយកដ្ឋានបាត់តាំង នាយកដ្ឋានផែនការហិរញ្ញកិច្ច វិទ្យាស្ថានស្រាវជ្រាវគ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ មជ្ឈមណ្ឌលចែកផ្សាយបណ្ណាល័យ នាយកដ្ឋានចំនេះទូទៅនិងមត្តេយ្យសិក្សា មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ហត្ថលេខា និងត្រា

តុល ឡោះ

* * *

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

ភ្នំពេញ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ១៩៩៦

ប្រកាសលេខ : ១៤១ ប្រក.វវស.ប

ស្តីពីការបង្កើតគណៈកម្មការមេប្រយោគទ្រទ្រង់និក្ខេបបទ
កំណែស្នាដៃសំរាប់ការប្រឡងបញ្ចប់បរិញ្ញា នៃមហាវិទ្យាល័យ
ស្ថាបត្យកម្មនិង នគរោបនីយវិទ្យា ឆ្នាំ ១៩៩៥ - ៩៦ របស់សាកល
វិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- តាមសំណើរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

សំរេច

ប្រការ១ : តែងតាំងលោក **អ៊ិត សារិទ្ធិ** ជាសមាជិកបន្ថែមលើសមាសភាពគណៈកម្មការមេប្រយោគ ទ្រទ្រង់និក្ខេបបទ និងកំណែស្នាដៃបច្ចេកទេស សំរាប់ការប្រឡងបញ្ចប់បរិញ្ញានៃមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរោបនីយវិទ្យា ដូចដែលបានចែងក្នុងប្រការ២ នៃប្រកាស លេខ១២២ ប្រក.វវស.ប ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

ប្រការ២ : តែងតាំងអ្នកស្រី **អ៊ិន យូរ៉ា** និងអ្នកស្រី **រស់ នាង** ជាសមាជិកបន្ថែមលើសមាសភាពគណៈកម្មការលេខាធិការដ្ឋាន ដូចដែលបានចែងក្នុងប្រការ៤ នៃប្រកាសខាងលើ ។

ប្រការ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

នុត ណារ៉ាង

* * *

ភ្នំពេញ,ថ្ងៃទី ១២ ខែ សីហា ឆ្នាំ១៩៩៦

ប្រកាសលេខ : ១៤៣ ប្រក.វវស.ប

អំពីការទទួលស្គាល់លទ្ធផលប្រឡងយកបរិញ្ញាប័ត្រសិល្បៈ

ផ្នែកបុរាណវិទ្យាជំនាន់ទី II ឆ្នាំសិក្សា ១៩៩៤-១៩៩៥ សម័យ

ប្រឡងថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩៩៥

* * *

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញកំណត់ហេតុ ស្តីពីការទ្រទ្រង់ និក្ខេបបទបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាប័ត្រសិល្បៈ ផ្នែកបុរាណវិទ្យា ជំនាន់ទី II ឆ្នាំ ១៩៩៤ - ៩៥
- បានឃើញ លិខិតលេខ ០១ សា.ក.ភ.វស.ប្រឡ. ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការសុំប្រកាសទទួលស្គាល់និស្សិតជំនាន់ទី ២ ចំនួន២៧នាក់ ត្រូវបានទទួលបរិញ្ញាប័ត្រសិល្បៈផ្នែកបុរាណវិទ្យា ឆ្នាំសិក្សា ១៩៩៤ - ៩៥

សំរេច

មាត្រា ១ : ទទួលស្គាល់ថាបានប្រឡងជាប់ បរិញ្ញាប័ត្រសិល្បៈផ្នែកបុរាណវិទ្យាជាស្ថាពរ នាសម័យ ប្រឡងថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ១៩៩៥ ដែលមាននិស្សិត ចំនួន២៧នាក់ :

ល.រ	លេខតុ	នាមនិងគោត្តនាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	ទីកន្លែងកំណើត	និទ្ទេស
១	១	កែវ ដាលីន	ស្រី	២១-៣-៧២	ភ្នំពេញ	មធ្យម
២	២	គង់ វីរៈ	ប្រុស	១២- ១២-៧២	ស្វាយរៀង	ល្អ
៣	៣	គឹម សេតារា	ប្រុស	១១-០១-៧០	ភ្នំពេញ	ល្អ
៤	៤	គី យ៉ាលីប	ប្រុស	២៤-១២-៥១	ភ្នំពេញ	ល្អប្រសើរ
៥	៥	គឹម មិញ	ប្រុស	១២-១២-៧១	សៀមរាប	ល្អប្រសើរ
៦	៧	គួ វ៉ុត	ប្រុស	១០-៩-៧១	កណ្ដាល	ល្អ
៧	៨	ច័ន្ទ សម្បត្តិ	ប្រុស	០១-០១-៦៩	ភ្នំពេញ	ល្អ
៨	៩	ជា នាង	ប្រុស	០៥-០២-៧៣	កណ្ដាល	មធ្យម
៩	១០	ឈឹម សុមុនី	ស្រី	២៥-១២-៧២	ភ្នំពេញ	ល្អ
១០	១១	តាន់ សុផល	ប្រុស	០៧-៣-៧១	សៀមរាប	ល្អបង្គួរ
១១	១២	ថោង ប៊ុនធឿន	ប្រុស	០៩-៧-៧២	កណ្ដាល	ល្អ
១២	១៣	ទា ភ៉ន់	ប្រុស	០១-០២-៧២	កណ្ដាល	ល្អប្រសើរ
១៣	១៤	ទីវ សុផល	ប្រុស	០១-០២-៧៣	កំពង់ឆ្នាំង	ល្អ
១៤	១៥	នៅ ចំរុង	ប្រុស	០១-៣-៧២	កណ្ដាល	ល្អ
១៥	១៦	ប្រាក់ សុវណ្ណរ៉ា	ប្រុស	១០-៧-៧១	ភ្នំពេញ	ល្អ
១៦	១៧	ប្រាក់ បូរសី	ស្រី	១៥-៦-៧២	ភ្នំពេញ	ល្អបង្គួរ
១៧	១៨	ប្រាជ្ញ សុផល	ប្រុស	០៦-៨-៦៧	ភ្នំពេញ	មធ្យម
១៨	២០	ផាន់ ណារី	ប្រុស	១៧-៣-៧០	ភ្នំពេញ	ល្អ
១៩	២១	យ៉ា ដា	ប្រុស	០៧-៥-៧២	កណ្ដាល	ល្អ
២០	២២	យិន រត្នធិន្នី	ស្រី	១៣-៣-៧២	កំពត	មធ្យម
២១	២៣	រស់ វិសុទ្ធ	ប្រុស	០៦-៥-៦៩	ភ្នំពេញ	ល្អ
២២	២៤	រ័ត្ន កេសរ៉ា	ប្រុស	២០-០១-៧២	ភ្នំពេញ	មធ្យម
២៣	២៥	លឹម ហាក់	ប្រុស	០៨-៧-៧១	សៀមរាប	ល្អ
២៤	២៧	សុក កាន់ណូរ៉ំ	ប្រុស	០១-១០-៧២	ភ្នំពេញ	មធ្យម
២៥	២៨	ហង្ស ចន្ទសោភា	ស្រី	២៨-៦-៧១	ភ្នំពេញ	ល្អ

២៦	២៩	អ៊ា ដារិទ្ធ	ប្រុស	១០-០៤-៧៣	ភ្នំពេញ	ល្អ
២៧	៣០	អ៊ឹម សុខរិទ្ធី	ប្រុស	៣០-០៤-៧២	ភ្នំពេញ	ល្អ

មាត្រា ២ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស សាកលវិទ្យាល័យ ភូមិន្ទ វិចិត្រសិល្បៈ មានភារកិច្ចអនុវត្តប្រកាសនេះ ។

មាត្រា ៣ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ហត្ថលេខា និងត្រា

នុត ណារ៉ាង

* * *

៥_ទីស្តីការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

ប្រកាស

ភ្នំពេញថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៧១៤ សករអ

ស្តីពីការបង្កើតការិយាល័យសុំកូនចិញ្ចឹម

* * *

រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ដែលប្រកាសអោយប្រើ តាមព្រះរាជក្រម លេខ នស/រកម/០១៩៦/១៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦
- តាមសំណូមពរចាំបាច់របស់ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

សំរេច

ប្រការ ១ : បង្កើតការិយាល័យមួយ ចំណុះនាយកដ្ឋានចូលនិវត្តន៍ សង្គ្រោះសង្គមដែលមានឈ្មោះថា «ការិយាល័យសុំកូនចិញ្ចឹម »ការិយាល័យនេះដឹកនាំដោយប្រធានមួយរូប និងអាចមានអនុប្រធានមួយរូបជាជំនួយការ ។

ប្រការ ២ : ការិយាល័យសុំកូនចិញ្ចឹមមានភារកិច្ចដូចខាងក្រោម ÷

១–រៀបចំកសាង និងអនុវត្តគោលការសុំកូនចិញ្ចឹមស្របពោមច្បាប់ជា ធរមាន ។

២–ទទួលពិនិត្យសំណុំលិខិតសុំកូនចិញ្ចឹមពីអ្នកស្នើសុំតាមការណែនាំរបស់ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ។

៣–ផ្តល់ពត៌មាននិងធ្វើសម្ភាសន៍ជាមួយអ្នកដាក់ពាក្យស្នើសុំកូនចិញ្ចឹម ។

៤–ត្រួតពិនិត្យអោយបានត្រឹមត្រូវនូវសំណុំលិខិតសុំកូនចិញ្ចឹម និងធ្វើកំណត់បង្ហាញជូនទៅថ្នាក់លើ ដើម្បីពិនិត្យសំរេច ។

៥–ទទួលខុសត្រូវក្នុងការបញ្ជូន និងតាមដានលិខិតស្នាមដែលពាក់ព័ន្ធនឹងការសុំកូនចិញ្ចឹម ទាំងក្នុងក្រសួង និងក្រៅក្រសួង រហូតដល់ទទួលបានសេចក្តីសំរេចជាស្ថាពរ ។

៦–ធ្វើទំនាក់ទំនងជាមួយមជ្ឈមណ្ឌលសង្គ្រោះទារក ដើម្បីបាន់ដឹងពីស្ថានភាពទូទៅនិង បរិមាណទារក នៅក្នុងមណ្ឌល ។

៧–គ្រប់គ្រងឯកសារ និងសំភារៈទាំងឡាយរបស់ការិយាល័យអោយបានត្រឹមត្រូវហ្មត់ចត់ ។

ប្រការ៣ : លោកប្រធានមន្ទីរ លោកប្រធាននាយកដ្ឋានចូលនិវត្តន៍ សង្គ្រោះសង្គម លោកប្រធានអធិការដ្ឋានសង្គមកិច្ច និងអតីតយុទ្ធជន រាជធានីភ្នំពេញ និងលោកប្រធានគ្រប់អធិការដ្ឋានសង្គមកិច្ចការងារ និងអតីតយុទ្ធជន, ខេត្ត-ក្រុង ត្រូវអនុវត្តន៍ប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

ប្រការ៤ : រាល់គោលការណ៍ទាំងឡាយពីមុនដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៥ : ប្រកាសនេះមានឥទ្ធិពលប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

ស៊ុយ សែម

* * *